# សំនួរប្រលងបញ្ចប់វគ្គ

## ? សំនួរសិក្សាទី ១

តើប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិទទួលបាននូវការត្រួតពិនិត្យដោយតុលាការ លើសេចក្តីសំរេចរដ្ឋបាល ដែរឬទេ?

ចូរដកស្រង់នូវបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធ ។

## ? សំនួរសិក្សាទី ២

ក្នុងការជំនុំជំរះរឿងក្តីមួយ តើការដែលមានអង្គជំនុំជំរះដែលមានចៅក្រម ៣រូប មានអត្ថប្រយោជន៏អ្វីជាជាងអង្គជំនុំជំរះដែលមានចៅក្រមតែ ១រូប?

## ? សំនួរសិក្សាទី ៣

តើហេតុអ្វីបានជា ដំណើរការនីតិវិធីទាំងអស់ដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុពិធីសារ ហើយនិងឯកសារទាំងអស់ដែលត្រូវរក្សាទុកក្នុងសុំណុំរឿងឱ្យបានត្រឹមត្រូវនោះ មានសារៈសំខាន់ម្ល៉េះ?

## ? សំនួរសិក្សាទី ៤

ការអនុវត្តន៏ការងាររបស់ចៅក្រម ១រូប ត្រូវបានត្រួតពិនិត្យដោយតួអង្គជាច្រើន ។

រៀបរាប់ឈ្មោះតួអង្គទាំងនោះយ៉ាងហោចណាស់ឱ្យបាន ៥ និងពិពណ៌នាអំពីរបៀបដែលពួកគេធ្វើការត្រួតពិនិត្យទៅលើចៅក្រម ។

## ? សំនួរសិក្សាទី ៥

តើហេតុអ្វីសាលក្រមត្រូវតែផ្តល់ហេតុផល?

## ? សំនួរសិក្សាទី ៦

ល្បឿនស្មើគ្នានៅក្នុងការកាត់ក្តីមួយ មានន័យថា ការកាត់ក្តីនោះ មិនត្រូវប្រព្រឹត្តទៅ យឺតពេក ហើយក៏កុំ លឿនពេកដែរ ។

រៀបរាប់:

ក) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយលឿន និង

ខ) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយមិនលឿនពេក

## ? សំនួរសិក្សាទី ៧

នៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ជនជាប់ចោទនិយាយថា គាត់បានផ្ដល់ចំលើយសារភាពរបស់គាត់ ក៏ព្រោះតែ គាត់ត្រូវធ្វើទារុណកម្មដោយប៉ូលិស ។

តើមេធាវីការពារក្ដីអាចធ្វើអ្វីបានខ្លះ? រៀបរាប់នូវមធ្យោបាយនានាទាំងអស់ដែលអាចធ្វើទៅបាន!

## ? សំនួរសិក្សាទី ៨

ចៅក្រម បានសាកសួរសាក្សីម្នាក់នៅក្នុងបន្ទប់របស់គាត់ ។ ជនជាប់ចោទ និងមេធាវីការពារក្ដី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្ដាប់ការសួរដេញដោលនោះទេ ។

តើចៅក្រមរូបនេះ បានបំពានទៅលើសិទ្ធិណាមួយរបស់ជនជាប់ចោទ?

ចូរដកស្រង់នូវបទបញ្ញត្តិនានាដែលពាក់ព័ន្ធ!

## ? សំនួរសិក្សាទី ៩

ដើម្បីឱ្យកាន់តែមានឯករាជភាព តើគេគួរកែប្រែ សមាសភាពនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងណាឱ្យកាន់តែប្រសើរ? ផ្ដល់ហេតុផលចំពោះសំណើរបស់អ្នក ។

## ? សំនួរសិក្សាទី ១០

តើ "គោលការណ៍នៃការត្រួតពិនិត្យ និងធ្វើឱ្យមានតុល្យភាព" មានន័យយ៉ាងដូចម្ដេច?

តើហេតុអ្វីបានជា គោលការណ៍នេះត្រូវបានគេបង្កើតឡើង?

## ? សំនួរសិក្សាទី ១១

តើអំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ធ្វើការត្រួតពិនិត្យគ្នាទៅវិញទៅមក យ៉ាងដូចម្ដេចខ្លះ?

## ? សំនួរសិក្សាទី ១២

តើអ្វីខ្លះទៅជាមុខងារសំខាន់ៗរបស់គណៈមេធាវី?